

# ញត្តិជូនលោក ម៉ៃឃើល ផុមភេអូ (Michael R. Pompeo)
## រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក
## « ពលរដ្ឋខ្មែរមានសង្ឃឹមជាថ្មី និងមិនឯកោ »

យើងខ្ញុំ ជាពលរដ្ឋខ្មែរ-អាមេរិកាំង មកជួបជុំសម្តែងមតិនៅថ្ងៃនេះ ដើម្បីថ្លែងអំណរគុណ ចំពោះសហរដ្ឋអាមេរិកដែលតែងតែនៅជាមួយប្រជាពលរដ្ឋខ្មែរ ក្នុងការតស៊ូមតិដើម្បីយុត្តិធម៌សង្គម និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ យើងខ្ញុំសង្ឃឹមថា សហរដ្ឋអាមេរិកបន្តតួនាទីដ៏មានឥទ្ធិពលរបស់ខ្លួន ឱ្យកាន់តែសកម្មថែមទៀត ដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងស្តារប្រជាធិបតេយ្យកម្ពុជាឡើងវិញ ក្នុងនាមសហរដ្ឋអាមេរិក ជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស៍ឆ្នាំ១៩៩១ និងជាមហាអំណាចម្ចាស់ជំនួយដល់កម្ពុជា ព្រមទាំងជាដៃគូពាណិជ្ជកម្មដ៏ធំមួយរបស់កម្ពុជា ។

យើងខ្ញុំ សូមថ្លែងអំណរគុណ ចំពោះលោករដ្ឋមន្ត្រីក្រសួងការបរទេស **ម៉ៃឃើល ផុមភេអូ (Michael R. Pompeo) ដែលបានបង្ហាញជំហរដ៏មានឥទ្ធិពល ឆ្លើយតបនឹងសេចក្តីត្រូវការអន្តរាគមន៍របស់ប្រជាពលរដ្ឋខ្មែរ បន្ទាប់ពីខ្លឹមសារលិខិតរបស់ចលនានិស្សិតដើម្បីលទ្ធិប្រជាធិតបេយ្យ ដែលមានអត្ថន័យស្របគ្នា** ។ យើងខ្ញុំ ពេញចិត្តណាស់ ចំពោះការបញ្ជាក់ជំហរច្បាស់នៃសហរដ្ឋអាមេរិក តាមសាររបស់លោករដ្ឋមន្ត្រី ក្នុងសេចក្តីដើមថា **« យើងនឹងមិនលើកលែងឱ្យសកម្មភាពទាំងឡាយណា ដែលប្រឆាំងនឹងជនស្លូតត្រង់ ហើយសហរដ្ឋអាមេរិកនឹងឈរការពារប្រជាពលរដ្ឋខ្មែរជានិច្ច »** ។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណ ចំពោះលោក **រ៉ូប៊ឺត អេ. ដេស្ត្រូ** (Robert A. Destro) ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ទទួលបន្ទុកលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ ដែលបានរំឭករដ្ឋាភិបាលកម្ពុជាថា « **សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិសេរីភាពនៃការជួបជុំតវ៉ា មានចែងក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ។ សហរដ្ឋអាមេរិក ព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចាប់ខ្លួន អ្នកដែល**

**អនុវត្តសេរីភាពទាំងនេះ ហើយយើងទទូចឲ្យរដ្ឋាភិបាល ដោះលែងពួកគាត់ជាបន្ទាន់ និងអនុញ្ញាតឲ្យពួកគាត់អាចបញ្ចេញមតិបាន** » ។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណ ចំពោះលោកសមាជិកសភា ពីរដ្ឋកាលីហ្វ័រញ៉ា ប្រចាំតំបន់លេខទី៤៧ **អាឡែន ឡូវ៉េនថល** (Congressman Alan Lowenthal ) ដែលឈឺឆ្អាលលើកទឹកចិត្តប្រជាពលរដ្ឋខ្មែររងគ្រោះ នូវសាររបស់លោកថា « **សកម្មជនទាំងអស់ គួរទទួលបាននូវការសាទរ លើកទឹកចិត្ត គឺពុំមែនដាក់ពន្ធនាគារទេ ។ ពួកគាត់ គឺជាអនាគតកម្ពុជា** » ។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណ ចំពោះលោកស្រីសមាជិកសភា ពីរដ្ឋម៉ាសាជូសេត ប្រចាំតំបន់លេខទី០៣ **ឡូរី ត្រាហាន** (Congresswoman **Lori Trahan** ) ដែលចេញសេចក្តីថ្លែងការណ៍ជាបន្ទាន់ថា « **នាយករដ្ឋមន្ត្រី (ហ៊ុន សែន) មានកាតព្វកិច្ចលើកតម្កើងរដ្ឋធម្មនុញ្ញកម្ពុជា ជាឯកសារដែលធានាការសន្យានូវប្រជាធិបតេយ្យ ចំពោះប្រជាពលរដ្ឋខ្មែរ គឺជារដ្ឋធម្មនុញ្ញជាតិ ដែលលោក ហ៊ុន សែន មិនត្រឹមតែចុះហត្ថលេខាដោយដៃឯងប៉ុណ្ណោះទេ ប៉ុន្តែលោកខ្លួនឯងផ្ទាល់ ម្តងហើយម្តងទៀត ក៏បានធ្វើសច្ចាប្រណិធានការពារតម្លៃខ្លឹមសារថែមទៀត ។ ការបំពេញកតព្វកិច្ចតាមរដ្ឋនុញ្ញនេះ ត្រូវចាប់ផ្តើមពីការបញ្ចប់ការរំលោភបំពាននានា និងដោះលែងអ្នកទោសនយោបាយ ដោយឥតលក្ខខណ្ឌ** » ។

ខ្លឹមសារនៃសាររបស់លោករដ្ឋមន្ត្រី សាររបស់លោកឧបការី សាររបស់លោកសមាជិកសភា និងលោកស្រីសមាជិកសភា បានរំឭកយើងខ្ញុំឡើងវិញ នូវអនុសាសន៍របស់អ្នកសិក្សាស្រាវជ្រាវតំបន់អាស៊ីនៃមូលនិធិបេតិកភណ្ឌ (**The Heritage Foundation**) លោក **វ៉លទ័រ ឡូម៉ែន** (**Walter Lohman**) និងអ្នកស្រី **អូលីវា អ៊ីនូស** (**Olivia Enos**) អំពីសារៈសំខាន់នៃតួនាទីសហរដ្ឋអាមេរិក ចំពោះកម្ពុជា ។ និក្ខេបបទ របស់ពួកគាត់ ដែលបានផ្សព្វផ្សាយលើគេហទំព័រមូលនិធិបេតិកភណ្ឌ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ពន្យល់ថា « អ្វីដែលកើតឡើងនៅកម្ពុជា គឺមានសារៈសំខាន់ចំពោះ សហរដ្ឋអាមេរិក ។ ពីសង្គ្រាមវៀតណាម ដល់សង្គ្រាមត្រជាក់ និងតួនាទីក្នុងអាស៊ាន កម្ពុជាបានក្លាយជាផ្នែកមួយដ៏មានសារៈសំខាន់ នៅក្នុងគោលនយោបាយការបរទេសសហរដ្ឋអាមេរិក » ។

ជាក់ស្តែងណាស់ សហរដ្ឋអាមេរិកបានរួមចំណែកដ៏ធំធេង ជាមួយបណ្តាប្រជាជាតិនានា អង្គការសហប្រជាជាតិ និងភាគីជម្លោះខ្មែរទាំងអស់ បញ្ចប់សង្គ្រាមរាំរ៉ៃនៅកម្ពុជា, ផលិតបាននូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឆ្នាំ១៩៩១សម្រាប់កម្ពុជា, នាំឲ្យប្រជាពលរដ្ឋខ្មែរ ស្គាល់សិទ្ធិសេរីភាពជាម្ចាស់ប្រទេស ក្នុងការសម្រេចចិត្តបែបប្រជាធិបតេយ្យ តាមរយៈការបោះឆ្នោតប្រជាធិបតេយ្យជាលើកដំបូងឆ្នាំ១៩៩៣ ដែលរៀបចំដោយអង្គការសហប្រជាជាតិ (អ៊ុនតាក់ UNTAC), និងបាននាំសិទ្ធិអធិបតេយ្យជាតិ ឲ្យប្រទេសកម្ពុជា ។ ទាំងអស់នេះ គឺជាសេចក្តីប្រថ្នាចង់បានបំផុត របស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលសហរដ្ឋអាមេរិក បណ្តាប្រជាជាតិនានា និងអង្គការសហប្រជាជាតិ ជួយបំពេញឲ្យប្រជាជាតិខ្មែរ ។

យើងទាំងអស់គ្នា ជាប្រជាពលរដ្ឋខ្មែរ បានដឹងថា បាប់តាំងពីកម្ពុជាមានរដ្ឋាភិបាលក្រោយការបោះឆ្នោតឆ្នាំ១៩៩៣មក រដ្ឋាភិបាលនិងប្រជាពលរដ្ឋអាមេរិក ជួយជ្រោមជ្រែងអភិវឌ្ឍន៍ប្រទេសកម្ពុជាលើគ្រប់វិស័យ ទាំងក្របខណ្ឌរដ្ឋាភិបាល និងសង្គមស៊ីវិល មានតម្លៃទឹកប្រាក់ប្រមាណជិត១០០លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២០ឆ្នាំមកនេះ ។ ជំនួយទាំងនេះ ផ្តល់ឲ្យកម្ពុជាតាមរយៈកម្មវិធីផ្សេងៗ ជាពិសេស USAID ដើម្បីអនុវត្តគម្រោងដោះមីន ការការពារបរិស្ថានទូទៅ ការបង្ការគ្រោះមហន្តរាយ វិស័យអប់រំសិក្សា វប្បធម៌ សុខភាពសាធារណៈ ការពង្រឹងប្រព័ន្ធយុត្តិធម៌ ការលើកតម្កើងសិទ្ធិមនុស្ស សិទ្ធិការងារសហជីពកម្មករ លទ្ធិប្រជាធិបតេយ្យ ហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មកសិកម្ម និងអភិវឌ្ឍន៍ជនបទ ... រហូតដល់ជំនួយ សេដ្ឋកិច្ចពាណិជ្ជកម្ម ដូចជា កម្មវិធីអនុគ្រោះពន្ធហៅកាត់ថា ជីអេសភី(GSP) ជាដើម ។

បន្ថែមលើជំនួយមនុស្សធម៌ជារូបវ័ន្តទាំងនេះ សារពីលោកនិងលោកស្រី ក្នុងតួនាទីជាន់ខ្ពស់ នៃសហរដ្ឋអាមេរិក នៅចំស្ថានភាពប្រជាពលរដ្ឋខ្មែរទូទៅ ដែលកំពុងធ្លាក់យ៉ាប់យ៉ឺនខ្លាំង និងត្រូវការជំនួយអន្តរាគមន៍ជាចាំបាច់នោះ ពិតជាលើកទឹកចិត្តប្រជាពលរដ្ឋខ្មែរ ឲ្យមានសេចក្តីសង្ឃឹមកាន់តែខ្លាំង ចំពោះការបន្តតស៊ូសកម្ម លើចក្ខុវិស័យផ្លាស់ប្តូរស្ថានការណ៍កម្ពុជា ចេញពីអំណាចបុគ្គលនិយម ។ សាររបស់លោកនិងលោកស្រី ធ្វើឲ្យប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន ដឹងថា ពួកគាត់ប្រឹងតស៊ូដោយមិនឯកោឡើយ ហើយសហរដ្ឋអាមេរិក ទាំងរដ្ឋាភិបាល សភា និងពលរដ្ឋ ឈរនៅជាមួយប្រជាពលរដ្ឋខ្មែរជានិច្ច លើការត្រួសត្រាយផ្លូវទៅកាន់ ការស្តារ លទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីនិងផុយស្រួចបំផុតរបស់កម្ពុជា ។

សូមលោក **ម៉ៃឃើល ផុមភេអូ** រដ្ឋមន្ត្រីក្រសួងការបរទេស រដ្ឋាភិបាល សភាទាំងពីរ និង ប្រជាពលរដ្ឋ នៃសហរដ្ឋអាមេរិក ទទួលនូវការគោរពអរគុណអំពីយើងខ្ញុំ ។

ធ្វើនៅរដ្ឋធានីវ៉ាស៊ីតុន ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

**ហត្ថលេខា**

(ហត្ថលេខា និងឈ្មោះនៅលើលិខិតដើមជាភាសាអង់គ្លេស)